# គ្រួសារប្រពៃ កូនវៃឆ្លាត

## ការណែនាំសម្រាប់ក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) - ការចុះទៅជួបស្ត្រីតាមផ្ទះ

នៅពេលដែលអ្នកបានកំណត់អត្តសញ្ញាណស្ត្រីម្នាក់នៅក្នុងតំបន់របស់អ្នកដែល
- ជាស្ត្រីមានផ្ទៃពោះច្រើនជាង ៣០សប្តាហ៍
- ជាស្ត្រីដែលបានសម្រាលកូនក្នុងរយៈពេល ៦ខែចុងក្រោយ

អ្នកគួរតែទៅចុះជួបស្ត្រីនៅផ្ទះរបស់នាង។ ប្រសិនបើអ្នកមានវិធីរៀបចំការចុះជួបតាមផ្ទះទុកជាមុន សូមធ្វើចុះ។ បើមិនដូច្នេះទេ សូមទៅផ្ទះស្ត្រី នៅពេលថ្ងៃ។ នៅពេលអ្នកជួបស្ត្រីនៅមាត់ទ្វារ សូមណែនាំខ្លួនអ្នក។

“ ជម្រាបសួរ ខ្ញុំឈ្មោះ............ហើយខ្ញុំជាក្រុមទ្រទ្រង់សុខភាពភូមិក្នុងតំបន់នេះ។ តើប្អូនមានពេល ៣០-៤៥ នាទី ដើម្បីពិភាក្សាអំពី កម្មវិធី “ គ្រួសារប្រពៃ កូនវៃឆ្លាត ” ដែលជាកម្មវិធីផ្ញើសារសម្លេងតាមទូរស័ព្ទ ដោយឥតគិតថ្លៃ ដើម្បីជួយសុខភាព និងអាហារូបត្ថម្ភរបស់ប្អូន និងកូន ដែរឬទេ ?

បើសិនស្ត្រីរវល់មិនអាចជួបបានទេ សូមធ្វើការណាត់ជួបលើកក្រោយទៀត ។ បើស្ត្រីព្រមឲ្យជួប ត្រូវធ្វើកិច្ចស្វាគមន៍ ដោយរាក់ទាក់ជាមួយស្ត្រី ដើម្បីបង្កើតបរិយាកាសស្និទ្ធស្នាល ។

### ជំហានទី ១ ៖ កម្រងសំនួរវាយតម្លៃដើមគ្រា

“ សូមអរគុណចំពោះការចំណាយពេលចូលរួមនៅថ្ងៃនេះ។ នៅក្នុងការខិតខំប្រឹងប្រែងរបស់ខេត្ត ក្នុងការលើកកម្ពស់សុខភាពរបស់ម្តាយ និងទារក ថ្ងៃនេះខ្ញុំនៅទីនេះដើម្បីប្រាប់អ្នកអំពី កម្មវិធី “ គ្រួសារប្រពៃ កូនវៃឆ្លាត ” ដែលជាកម្មវិធីផ្ញើសារជាសម្លេងតាមទូរស័ព្ទ ដោយឥតគិតថ្លៃដែលផ្តល់ឱ្យអ្នកនូវការរំលឹក និងសារគន្លឹះណែនាំខ្លីៗអំពីរបៀបធ្វើឱ្យអ្នក និងកូនមានសុខភាពល្អ។ យ៉ាងមិចដែរ ប្អូនចាប់អារម្មណ៍ទេ ?

ល្អណាស់ ! តើអ្នកធ្លាប់បានលឺឈ្មោះកម្មវិធី “ គ្រួសារប្រពៃ កូនវៃឆ្លាត ” ទេ ?

ប្រសិនបើម្តាយ
- មិនធ្លាប់បានចុះឈ្មោះសម្រាប់ IVRs ពីមុនមកទេ និង
- មិនទាន់បានឃើញប្រតិទិនតាមដានសុខភាពកូនពីមុនមកទេ

សូមបំពេញកម្រងសំណួរសម្ភាសន៍ស្ត្រី បើស្ត្រីមិនទាន់បានចុះឈ្មោះក្នុងកម្មវិធីពីមុន ។

ប្រសិនបើម្តាយបានចុះឈ្មោះក្នុងកម្មវិធីរួចហើយ សូមសួរគាត់អំពីបទពិសោធន៍របស់គាត់។ សូមប្រមូលមតិត្រលប់ដែលអាចជួយកែលម្អកម្មវិធី បន្ទាប់មក សូមអរគុណ ស្ត្រីសម្រាប់ពេលវេលារបស់គាត់ និងជម្រាបលាគាត់។

### ជំហានទី ២ ៖ ការណែនាំអំពីកម្មវិធី “ គ្រួសារប្រពៃ កូនវៃឆ្លាត ”

“ សូមអរគុណចំពោះពេលវេលារបស់ប្អូនក្នុងការឆ្លើយសំណួរ - ព័ត៌មានរបស់ប្អូននឹងមានប្រយោជន៍ក្នុងការកែលម្អកម្មវិធីរបស់យើងនាពេលអនាគត។

“ ឥឡូវនេះខ្ញុំសូមប្រាប់ប្អូន អំពីកម្មវិធី “ គ្រួសារប្រពៃ កូនវៃឆ្លាត ” ។ វាគឺជាកម្មវិធីផ្ញើសារជាសម្លេងតាមទូរស័ព្ទដោយឥតគិតថ្លៃ។ ជាមួយនឹងកម្មវិធីនេះ ប្អូននឹងទទួលបានការហៅទូរស័ព្ទដោយស្វ័យប្រវត្តិ និងសារជាអក្សរ ( SMS )១-២ ដងក្នុងមួយសប្តាហ៍ក្នុងរយៈពេល ៧ខែដំបូងនៃអាយុរបស់កូនរបស់ប្អូន។
តើអ្នកចង់ចុះឈ្មោះសម្រាប់កម្មវិធីឥឡូវនេះទេ ?

### ជំហានទី ៣ ៖ ចុះឈ្មោះម្តាយសម្រាប់កម្មវិធី “ គ្រួសារប្រពៃ កូនវៃឆ្លាត ”




សូមប្រើទូរស័ព្ទរបស់អ្នក ឬទូរស័ព្ទរបស់ស្ត្រី ដើម្បីស្កេន QR កូដ លើប្រតិទិនតាមដានសុខភាពម្តាយ និងកូន ឬវាយអាសយដ្ឋានគេហទំព័រ HTTPS://BIT.LY/3RQHODK ដើម្បីចូលប្រើទម្រង់ចុះឈ្មោះ។
បំពេញទម្រង់បែបបទ ដែលត្រូវការព័ត៌មានខាងក្រោម ៖
- ឈ្មោះស្ត្រី
- លេខទូរស័ព្ទរបស់ស្ត្រី
- ថ្ងៃត្រូវសម្រាលរបស់ទារក ឬថ្ងៃខែឆ្នាំកំណើតរបស់ទារក
- ទីតាំងខេត្តរបស់ស្ត្រី

“ ដាក់ស្នើ ” ទម្រង់ ឬដោយប្រើទូរស័ព្ទរបស់ម្តាយ សូមជួយគាត់ឱ្យចុចលេខឥតគិតថ្លៃនៅលើប្រតិទិនតាមដានសុខភាពកូន។ សូមជួយគាត់តាមការចាំបាច់ ក្នុងការបញ្ចូលព័ត៌មានចុះឈ្មោះដោយការចុចលើប៊ូតុងលើទូរស័ព្ទដៃរបស់គាត់។

“ ល្អណាស់ ! ឥឡូវនេះប្អូនបានចុះឈ្មោះសម្រាប់កម្មវិធី “ គ្រួសារប្រពៃ កូនវៃឆ្លាត ” ហើយ។ កុំភ្លេចស្តាប់ទូរស័ព្ទណា ហើយស្តាប់សារឲ្យចប់។ ប្អូននឹងទទួលបានការហៅទូរស័ព្ទនៅម៉ោង ៧ព្រឹក ហើយប្រសិនបើប្អូន មិនបានលើក ទូរស័ព្ទទេ ប្អូននឹងទទួលបានហៅទូរស័ព្ទម្តងទៀតនៅម៉ោង ៩ព្រឹក ១២ថ្ងៃត្រង់ និងម៉ោង ៦ល្ងាច។

ប្រសិនបើប្អូនមិនបានលើកទូរស័ព្ទខាងលើទេ ប្អូននឹងមិនទទួលបាន( រំលង )សារមួយ តែប្អូននឹងទទួលបានសារថ្មីបន្តបន្ទាប់ទៀត។ កុំភ្លេចចាំទទួលទូរស័ព្ទណា ! ការហៅទូរស័ព្ទម្តងៗវាមានប្រយោជន៍ និងមានតែម្តងគត់។ ប្រសិនបើប្អូនលែងចង់ទទួលសារសារជាអក្សរ ( SMS )នេះ ប្អូនអាចដកឈ្មោះចេញនៅពេលណា ក៏បាន។

សូមប្រាប់ស្ត្រី ឱ្យដឹងថា ពួកគាត់ និងអ្នកផ្សេងទៀតក៏អាចចុះឈ្មោះ ដោយខ្លួនឯងបានដែរ ជាពិសេសប្តីរបស់គាត់។ ពួកគាត់អាច ចុចតំណភ្ជាប់ ឬស្កេន QR កូដ ឬហៅទៅកាន់លេខទូរស័ព្ទដោយឥតគិតថ្លៃដើម្បីចុះឈ្មោះ ដែលមាននៅលើឧបករណ៍ប្រតិទិនតាមដានសុខភាពមាតា និងទារក។

### ជំហានទី ៤ ៖ ប្រតិទិនតាមដានសុខភាពម្តាយ និងកូន

សូមបង្ហាញម្តាយនូវឧបករណ៍ប្រតិទិនតាមដានសុខភាពកូន។
- សូមបើកវាឡើង ហើយបង្ហាញគាត់នូវអាកប្បកិរិយាប្រចាំខែ និងរបៀប 'ពិនិត្យ' រាល់ឥរិយាបថដែលនាំឱ្យមានសុខភាពល្អដែលគាត់បានធ្វើ
- សូមលើកទឹកចិត្តគាត់ឱ្យបង្ហាញប្រតិទិនតាមដានសុខភាពកូននៅកន្លែងដែលអាចមើលឃើញនៅក្នុងផ្ទះ ដើម្បីឱ្យគាត់ចងចាំក្នុងការតាមដាន និងពិនិត្យមើលឥរិយាបថនីមួយៗ។



### ជំហានទី ៥ ៖ អរគុណ និងលើកទឹកចិត្តឱ្យមានការទៅពិនិត្យផ្ទៃពោះមុន/ក្រោយសម្រាល

“ សូមអរគុណសម្រាប់ពេលវេលារបស់ប្អូននៅថ្ងៃនេះ ហើយខ្ញុំសង្ឃឹមថាកម្មវិធីផ្ញើសារជាសម្លេងតាមទូរស័ព្ទនេះ និងប្រតិទិនតាមដានសុខភាពម្តាយ និងកូន មានប្រយោជន៍សម្រាប់ប្អូន ក្នុងការធ្វើឱ្យប្អូន និងកូនមានសុខភាពល្អ។

អាស្រ័យលើដំណាក់កាលនៃការមានផ្ទៃពោះរបស់ម្តាយ ឬអាយុរបស់ទារក សូមរំលឹកម្តាយអំពីការទៅពិនិត្យផ្ទៃពោះមុន/ក្រោយសម្រាលនាពេលខាងមុខ ដូចដែលបានសម្គាល់នៅក្នុងប្រតិទិនតាមដានសុខភាពម្តាយ និងកូន ហើយលើកទឹកចិត្តគាត់ឱ្យចូលរួម។



USAID
ជំនួយពីប្រជាជនអាមេរិក

psi
Cambodia

# សន្លឹកកិច្ចការនៃការអនុវត្តសកម្មភាព សម្រាប់ក្រុមទ្រទ្រង់សុខភាពភូមិ

ឈ្មោះភូមិ: .........................................................................

ខេត្ត:.................................................................................

លេខទូរស័ព្ទរបស់ភ្នាក់ងារអប់រំសុខភាព:

.................................................................................

.................................................................................

.................................................................................

.................................................................................

## ផ្នែកទី១៖ ការបិទផ្ទាំងរូបភាព

|   **ទីតាំង**<br>តើអ្នកនឹងបិទផ្ទាំងរូបភាពនៅទីតាំងណាក្នុងភូមិរបស់អ្នក ? | **ចំនួន**<br>តើអ្នកត្រូវការចំនួនប៉ុន្មាន ? |
|---|---|
| ............................................. | ................. |
| ............................................. | ................. |
| ............................................. | ................. |
| ............................................. | ................. |
| ............................................. | ................. |
| ............................................. | ................. |
| ............................................. | ................. |

## ស្វែងរកក្រុមគោលដៅរបស់អ្នក

### តើអ្នកនឹងកំណត់រកស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយសម្រាលនៅក្នុងភូមិរបស់អ្នកដោយរបៀបណា ?



តើអ្នកអាចសួរអ្នកណា ?

.................................................................

.................................................................

តើបណ្តាញ និងក្រុមណាដែលអ្នកនឹងប្រើដើម្បីប្រមូលពត៌មានរបស់ស្ត្រីគោលដៅនេះ ?

.................................................................

.................................................................

តើពួកគេអាចជួបជុំគ្នានៅទីណា ?

.................................................................

.................................................................

តើអ្នកនឹងចែករំលែកព័ត៌មានលម្អិតអំពីទំនាក់ទំនងរបស់អ្នកជាមួយភូមិដោយរបៀបណា ដើម្បីឱ្យស្ត្រីមានផ្ទៃពោះ (៣០សប្តាហ៍ឡើងទៅ) និងស្ត្រីដែលមានកូនតិចជាង ឬស្មើ ៦ខែ ទាក់ទងអ្នកបាន

.................................................................

.................................................................

## ផ្នែកទី៣៖ បញ្ជីត្រួតពិនិត្យការអនុវត្តសម្រាប់ក្រុមទ្រទ្រង់សុខភាពភូមិ (VHSG)

**បំពេញជំហាននីមួយៗខាងក្រោមដើម្បីធានាថាអ្នកនឹងអនុវត្តកម្មវិធី “ គ្រួសារប្រពៃកូនវៃឆ្លាត “ បានជោគជ័យ។**

- [ ] បិទផ្ទាំងរូបភាពនៅក្នុងភូមិនៅទីតាំងដែលស្ត្រីក្រុមគោលដៅរបស់យើងអាចមើលឃើញ។
- [ ] ទាក់ទងថ្នាក់ដឹកនាំមូលដ្ឋាន និងប្រាប់ពួកគេអំពីអន្តរាគមន៍នៃកម្មវិធី “គ្រួសារប្រពៃកូនវៃឆ្លាត" របស់យើង ដើម្បីលើកទឹកចិត្តពួកគេឱ្យជួយស្វែងរកស្ត្រីក្រុមគោលដៅរបស់យើង ។
- [ ] ពិនិត្យកន្លែងប្រជុំនិងទីតាំងក្នុងសហគមន៍ ហើយចូលរួមការជួបជុំទាំងនោះ ដើម្បីបានជួបជាមួយ ស្ត្រីក្រុមគោលដៅរបស់យើង ។
- [ ] ធ្វើការចុះជួបស្ត្រីក្រុមគោលដៅ តាមផ្ទះ។
- [ ] ចែករំលែកការវាយតម្លៃដើមគ្រាជាមួយភ្នាក់ងារអប់រំសុខភាពរបស់អ្នក។

USAID
ជំនួយពីពលរដ្ឋអាមេរិក
psi
Cambodia

# គ្រួសារប្រពៃ កូនវៃឆ្លាត

## ការណែនាំសម្រាប់ពេទ្យឆ្មបមណ្ឌលសុខភាព

ពេលជួបជាមួយម្ដាយ

- ស្ត្រីមានផ្ទៃពោះអាយុ ៧ខែកន្លះ ឬ៣០សប្ដាហ៍ឡើងទៅ
- ស្ត្រីមានកូនអាយុតិចជាង ឬស្មើ ៦ខែ

អ្នកគួរតែប្រាប់ស្ត្រីអំពីកម្មវិធី "គ្រួសារប្រពៃ កូនវៃឆ្លាត" **ឥតគិតថ្លៃ** ហើយចុះឈ្មោះដោយប្រើលេខទូរស័ព្ទរបស់ស្ត្រីសម្រាប់កម្មវិធីនេះ។

## ជំហានទី ១ ៖ ការណែនាំអំពីកម្មវិធី គ្រួសារប្រពៃកូនវៃឆ្លាត

" សូមអរគុណចំពោះការចូលរួមការត្រួតពិនិត្យផ្ទៃពោះមុន/ក្រោយសម្រាល ( **ANC/PNC** ) នេះ។ មុនពេលប្អូនចាកចេញពីមណ្ឌលសុខភាពនេះ ខ្ញុំចង់ប្រាប់អ្នក អំពីកម្មវិធី "គ្រួសារប្រពៃ កូនវៃឆ្លាត "ដែលជាកម្មវិធីផ្ញើសារជាសម្លេងតាមទូរស័ព្ទ ដោយឥតគិតថ្លៃ ដែលផ្ដល់ឲ្យស្ត្រីជាម្ដាយ នូវសារអប់រំដើម្បីរំលឹក និងធានាថាម្ដាយ និងកូនមានសុខភាពល្អ។ តើប្អូនចាប់អារម្មណ៍ទេ?

ខ្ញុំអាចចុះឈ្មោះប្អូន សម្រាប់កម្មវិធីនេះដោយឥតគិតថ្លៃឥឡូវនេះ ដើម្បីឱ្យប្អូនទទួលបានសារជាសម្លេងតាមទូរស័ព្ទ និងជាសារអក្សរ (**SMS**)ជាមួយការរំលឹក និងដំបូន្មានដើម្បីជួយឱ្យប្អូន មានសុខភាពល្អ និងជួយឱ្យកូនរបស់ប្អូន ធំឡើងក្លាយជាក្មេងឆ្លាត។

ជាមួយនឹងកម្មវិធីនេះ ប្អូននឹងទទួលបានការហៅទូរស័ព្ទដោយស្វ័យប្រវត្តិ និងសារជាអក្សរ (**SMS**)១-២ ដងក្នុងមួយសប្ដាហ៍ក្នុងរយៈពេល ៧ខែដំបូងនៃអាយុរបស់កូនរបស់ប្អូន។ ប្អូននឹងទទួលបានការហៅទូរស័ព្ទនៅម៉ោង ៧ព្រឹក ហើយប្រសិនបើប្អូន មិនបានលើកទូរស័ព្ទទេ ប្អូននឹងទទួលបានហៅទូរស័ព្ទម្ដងទៀតនៅម៉ោង ៩ព្រឹក ១២ថ្ងៃត្រង់ និងម៉ោង ៦ល្ងាច។
ប្រសិនបើប្អូនមិនបានលើកទូរស័ព្ទខាងលើទេ ប្អូននឹងមិនទទួលបាន(រំលង) សារមួយតែប្អូននឹងទទួលបានសារថ្មីបន្តបន្ទាប់ទៀត។ កុំភ្លេចចាំទទួលទូរស័ព្ទណា! ការហៅទូរស័ព្ទម្ដងៗវាមានប្រយោជន៍ និងមានតែម្ដងគត់។ ប្រសិនបើប្អូនលែងចង់ទទួលសារនេះ ប្អូនអាចដកឈ្មោះចេញនៅពេលណាក៏បាន។

ខ្ញុំនឹងចុះឈ្មោះឲ្យប្អូនសម្រាប់កម្មវិធីនេះឥឡូវ តើប្អូនយល់ព្រមទេ?

**កំណត់ចំណាំសម្រាប់ឆ្មបមណ្ឌលសុខភាព ៖ គួរតែបំពេញទម្រង់បែបបទនេះសម្រាប់ម្ដាយគ្រប់រូបដែលអ្នកបានប្រាប់អំពីកម្មវិធី "គ្រួសារប្រពៃ កូនវៃឆ្លាត" ដូច្នេះយើងអាចកត់ត្រាពីការ ចូលរួមរបស់ឆ្មប និងផ្ដល់ការទូទាត់ជូនឆ្មប។ ប្រសិនបើម្ដាយមិនចង់ទទួលបានសារ IVRS ឆ្មប អាចទុកកន្លែងបំពេញ លេខទូរស័ព្ទឱ្យនៅទំនេរ។**

## ជំហានទី ២ ៖ ចុះឈ្មោះស្ត្រីចូលក្នុងកម្មវិធី "គ្រួសារប្រពៃ កូនវៃឆ្លាត"

ប្រើទូរស័ព្ទ ឬកុំព្យូទ័ររបស់ឆ្មប រួចសូមចូលទៅកាន់ទម្រង់ ចុះឈ្មោះតាមអនឡាញ ៖ **HTTPS://BIT.LY/3RQHODK**

ឬ ស្កេននៅលើ **QR** កូដ ដែលមាននៅលើ ខិត្តប័ណ្ណបញ្ជូរតុឆ្មប

សូមបំពេញទម្រង់បែបបទអនឡាញ នូវព័ត៌មានខាងក្រោម ៖

- ឈ្មោះម្ដាយ
- ថ្ងៃសម្រាល/ថ្ងៃខែឆ្នាំកើតរបស់ទារក
- ទីតាំងខេត្តរបស់ស្ត្រី
- ឈ្មោះមណ្ឌលសុខភាព
- លេខទូរស័ព្ទស្ត្រី + ប្ដី ឬអ្នកថែទាំ (ប្រសិនបើពួកគេចង់បានសារ)

សូមលើកទឹកចិត្តស្ត្រី ឱ្យចុះឈ្មោះប្ដីរបស់គាត់ និងមនុស្សផ្សេងទៀតដែលនឹងមើលថែទាំទារក។ ព័ត៌មានសុខភាពនៅក្នុងកម្មវិធីនេះ មានសារៈសំខាន់ណាស់ដែលគ្រប់គ្នាត្រូវដឹង!

"ដាក់ស្នើ" ទម្រង់អនឡាញនោះ ដូចនេះស្ត្រីចុះឈ្មោះរួចហើយ!

សូមប្រាប់ស្ត្រី ឲ្យដឹងថា គាត់នឹងទទួលទូរស័ព្ទដំបូង នៅព្រឹកស្អែក ម៉ោង ៧ព្រឹក។ ហើយត្រូវប្រាកដថាស្ត្រីទទួលទូរស័ព្ទនោះ និងស្ដាប់សារទាំងមូល។ ហើយស្ត្រីក៏មានជម្រើសក្នុងការស្ដាប់សារ ម្ដងទៀត ឬដកឈ្មោះចេញ( ឈប់ប្រើសេវានេះ )។

## ជំហានទី ៣៖ លើកទឹកចិត្តអ្នកដទៃឱ្យចុះឈ្មោះសម្រាប់កម្មវិធី "គ្រួសារប្រពៃ កូនវៃឆ្លាត"

សូមប្រាប់ស្ត្រី ឱ្យដឹងថា ពួកគាត់ និងអ្នកផ្សេងទៀតក៏អាចចុះឈ្មោះ ដោយខ្លួនឯងបានដែរ។ ពួកគាត់អាចចុចតំណភ្ជាប់ ឬស្កេន **QR** កូដ ឬហៅទៅកាន់លេខទូរស័ព្ទដោយឥតគិតថ្លៃដើម្បីចុះឈ្មោះ ដែលមាននៅលើឧបករណ៍ប្រតិទិនតាមដានសុខភាពមាតា និងទារក ដែលពួកគាត់ទទួលបានពីឆ្មប។

អ្នកប្រើប្រាស់ អាចធ្វើការចុះឈ្មោះដោយទូរស័ព្ទទៅកាន់លេខ **1800 201 938** ដោយឥតគិតថ្លៃ បន្ទាប់មកឆ្លើយសំណួរ តាមរយៈសារសម្លេង ឬប្រើប៊ូតុងចុចលេខនៅលើទូរស័ព្ទរបស់អ្នកប្រើប្រាស់តាមការណែនាំដើម្បីចុះឈ្មោះ។



## ជំហានទី ៤ ៖ ប្រតិទិនតាមដានសុខភាពម្ដាយ និងកូន



សូមចាំថាត្រូវផ្ដល់ឱ្យស្ត្រី នូវឧបករណ៍ប្រតិទិនតាមដានសុខភាពម្ដាយ និងកូនយកទៅផ្ទះ។

- សូមបើកវា ហើយបង្ហាញស្ត្រី នូវសកម្មភាពប្រចាំខែ និងរបៀប "គូសធីក" លើរាល់សកម្មភាពនាំមកនូវ សុខុមាលភាពដែលគាត់បានធ្វើ។



- សូមបង្ហាញស្ត្រី នូវលេខទូរស័ព្ទចុះឈ្មោះ ដោយខ្លួនឯង និងលេខ **QR** កូដសម្រាប់ស្កេន ហើយលើកទឹកចិត្តឱ្យគាត់ចុះឈ្មោះខ្លួនឯង ប្ដីរបស់គាត់និងអ្នកថែទាំផ្សេងទៀត ប្រសិនបើគាត់មិនទាន់បានចុះឈ្មោះអ្នកទាំងនោះ។



USAID
ជំនួយពីប្រជាជនអាមេរិក
psi Cambodia

# សន្លឹកកិច្ចការនៃការអនុវត្តសកម្មភាពសម្រាប់ឆ្មបមណ្ឌលសុខភាព

ឈ្មោះមណ្ឌលសុខភាព: ..........................................................

ឈ្មោះឆ្មប ......................................................................

..........................................................................................

លេខទូរស័ព្ទរបស់ភ្នាក់ងារអប់រំសុខភាព: ........................................

..........................................................................................

## ផ្នែកទី១៖ ការអនុវត្តផែនការ

| | | ផ្ទាំងរូបភាព<br>តើអ្នកនឹងប្រើឧបករណ៍នេះនៅទីតាំងណាក្នុងមណ្ឌលសុខភាព ? | ចំនួន<br>តើអ្នកត្រូវការចំនួនប៉ុន្មាន ? |
|---|---|---|---|
| សម្ភារតាំងលើតុរបស់ឆ្មប |   | ................................<br>................................<br>................................ | ..................<br>..................<br>.................. |
| ផ្ទាំងរូបភាព |   | ................................<br>................................<br>................................ | ..................<br>..................<br>.................. |
| ប្រតិទិនតាមដានសុខភាពម្តាយនិងកូន |  | ................................<br>................................<br>................................ | ..................<br>..................<br>.................. |

## ផ្នែកទី២៖ បញ្ជីត្រួតពិនិត្យការអនុវត្ត

**បំពេញជំហាននីមួយៗខាងក្រោមដើម្បីធានាថា មណ្ឌលសុខភាពរបស់អ្នកត្រូវបានរៀបចំរួចរាល់ក្នុងការផ្តល់អន្តរាគមន៍ លើគម្រោងសុខភាពមាតា ទារក និងអាហារូបត្ថម្ភ។**

- ☐ ប្រមូលក្រុមការងារឆ្មបរបស់អ្នក ហើយបង្ហាញពួកគេអំពីឧបករណ៍ទាំងអស់។ បង្រៀនពួកគេអំពីប្រព័ន្ធសារជាសម្លេងតាមទូរស័ព្ទ (IVRS) និងរបៀបបំពេញទម្រង់ចុះឈ្មោះ។
- ☐ បង្ហាញផ្ទាំងរូបភាព និង សម្ភារតាំងលើតុរបស់ឆ្មប នៅទីតាំងនៃការផ្តល់សេវា «មុនសម្រាល» «ពេលសម្រាល» និង «ក្រោយសម្រាល»។
- ☐ ទុកដាក់ ប្រតិទិនតាមដានសុខភាពមាតានិងកូននៅកន្លែងណាមួយដែលងាយស្រួលយក ហើយដាក់បង្ហាញវាខ្លះៗ នៅទីតាំង មុនសម្រាល និង ក្រោយសម្រាល។
- ☐ សាកល្បងប្រើប្រាស់ទម្រង់ចុះឈ្មោះនៅលើកុំព្យូទ័រ ឬទូរស័ព្ទរបស់អ្នក។
- ☐ ចុះឈ្មោះក្រុមការងារក្នុងមណ្ឌលសុខភាពរបស់អ្នកក្នុងប្រព័ន្ធសារជាសម្លេងតាមទូរស័ព្ទ (IVRS)។ វាមានប្រយោជន៍ក្នុងការទទួលបានបទពិសោធន៍ នៃការសាកល្បងសេវាកម្មនេះ ដែលអ្នកត្រូវផ្តល់អោយ អ្នកជំងឺរបស់អ្នក។



USAID ជំនួយពីប្រជាជនអាមេរិក

psi Cambodia